អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) បានចេញសេចក្តីសម្រេចរបស់ខ្លួនដោយទាត់ចោលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) ដែលស្នើឲ្យ អ.ជ.ត.ក បញ្ជូនសំណុំរឿងប្រឆាំង មាស មុត ទៅអង្គជំនុំជម្រះសាលាដំបូង (“អ.ជ.ស.ដ”) ដើម្បីធ្វើការជំនុំជម្រះ។ បណ្តឹងសាទុក្ខនេះ ធ្វើឡើងដោយផ្អែកលើការរកឃើញជាឯកច្ឆន្ទរបស់ចៅក្រមអង្គបុរេជំនុំជម្រះ (“អ.ប.ជ”) ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង មាស មុត មានសុពលភាព ក៏ដូចជាក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលតម្រូវឲ្យសំណុំរឿងត្រូវបញ្ជូនទៅជំនុំជម្រះ វៀរលែងតែចៅក្រម អ.ប.ជ យ៉ាងហោចណាស់បួនរូបក្នុងចំណោមប្រាំរូប បដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលការនេះចៅក្រម អ.ប.ជ មិនបានធ្វើដូច្នេះឡើយ។

ចៅក្រម អ.ជ.ត.ក ទាំងអស់បានយល់ស្របថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ គឺត្រូវមានសវនាការលើពាក្យសុំរបស់ ស.ព.អ។ ដោយមានចៅក្រមមួយរូបមិនយល់ស្រប អ.ជ.ត.ក បានសម្រេចលើផ្នែកពាក់ព័ន្ធថា ផ្នែកសម្រេចសេចក្តីរួមរបស់ អ.ប.ជ មិនបានរកឃើញជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពទេ ទោះបីចៅក្រម អ.ប.ជ គ្រប់រូបបានធ្វើការសម្រេចដូច្នេះក៏ដោយ។ អ.ជ.ត.ក ដែលសន្និដ្ឋានថា ដោយសារតែអវត្តមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដាច់ស្រេច និងអាចអនុវត្តបាន ព្រមទាំងការបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ បានផ្តល់នូវយុត្តិកម្មសម្រាប់ការបញ្ចប់សំណុំរឿងនេះ មុនមានការសម្រេចណាមួយនោះ គឺអាចនឹងធ្វើបានទាក់ទងនឹងពិរុទ្ធភាពរបស់ មាស មុត។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក គឺជាសេចក្តីសម្រេចចុងក្រោយ និងមិនអាចប្តឹងសាទុក្ខបានឡើយ។

នៅក្នុងមតិជំទាស់របស់គាត់ ចៅក្រម Maureen Harding Clark បានសន្និដ្ឋានថា សេចក្តីសម្រេចរបស់ចៅក្រម អ.ប.ជ មិនមានសុពលភាព ដោយហេតុថា វាមិនមានភាពច្បាស់លាស់ និងភាពស្ថាពរ។ គាត់ឯកភាពជាមួយនឹង ស.ព.អ ថា កិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក គឺជាច្បាប់គ្រឹះរបស់

តុលាការនេះ មិនមែនគោលនយោបាយជាតិរបស់កម្ពុជានោះទេ។ ទោះបីជាគាត់បញ្ជាក់ថា ឯកសារទាំងអស់នេះប្រមើលអំពីការអនុវត្តយន្តការស្វ័យប្រវត្តិដោយបញ្ជូនរឿងក្តីទៅជំនុំជម្រះ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលុបគាំទ្រឱ្យទម្លាក់ការចោទប្រកាន់យ៉ាងណាក៏ដោយ គាត់សន្និដ្ឋានថាករណីនេះមិនអាចអនុវត្តបានទេ ដោយសារតែភាពមិនចុះសម្រុងគ្នាដែលមិនអាចសម្រុះសម្រួលបានរវាងភាគីជាតិ និងភាគីអន្តរជាតិនៃ អ.វ.ត.ក។ គាត់បានសន្និដ្ឋានថា ការណ៍នេះមានន័យថា មិនមានវិធីប្រកដប្រជាមានអត្ថិភាពដើម្បីកែតម្រូវសេចក្តីសម្រេចដែលមានវិការៈរបស់ អ.ប.ជ ឡើយ ហើយផ្អែកលើមូលហេតុតែមួយនេះសម្រេចថារឿងក្តីគួរត្រូវបញ្ចប់។

វាមានសារសំខាន់សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត និងសង្គមកម្ពុជាជាទូទៅ ក្នុងការយល់អំពីអត្ថន័យនៃសេចក្តីសម្រេចលើកលែងចោទប្រកាន់របស់ អ.ជ.ត.ក ថាតើវាមានន័យបែបណានោះ។ អ.ជ.ត.ក មិនបានសន្និដ្ឋានថា មាស មុត គ្មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដ៏មហាធ្ងន់ធ្ងរ ដែលរូបគាត់ត្រូវបានចោទប្រកាន់នោះទេ រួមទាំងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាអំពើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ អ.ជ.ត.ក មិនបានធ្វើការសន្និដ្ឋានណាមួយលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ មាស មុត នោះទេ។ ផ្ទុយទៅវិញ សេចក្តីសម្រេចលើកលែងចោទប្រកាន់នេះមានន័យថា មិនមានការជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ដើម្បីធ្វើការសម្រេចតាមផ្លូវតុលាការលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ឡើយ។

ដូច្នេះ នៅពេលនេះ ការទទួលខុសត្រូវស្ថិតនៅលើតុលាការជាតិកម្ពុជា ក្នុងការផ្តល់យុត្តិធម៌ តាមរយៈការកំណត់ថាតើ មាស មុត ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដ៏មហាធ្ងន់ធ្ងរ នៅក្នុងការជំនុំជម្រះមួយដែលឯករាជ្យ ឥតលម្អៀង ដែលធ្វើការសម្រេចផ្អែកតែទៅលើច្បាប់ និងអង្គហេតុប៉ុណ្ណោះ និងការធានាឱ្យមានភាពត្រឹមត្រូវយុត្តិធម៌សម្រាប់គ្រប់ភាគីទាំងអស់ រួមទាំងភាគីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី៕

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh